**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

******

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៦.០៩២/០៨ គ.ជ.ប/អត្ត.៣ស**

ភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៨

# និយោជិត កម្មករ កម្មការិនី ត្រូវឈប់សម្រាកដើម្បីចូលរួមបោះឆ្នោត

យោងតាមសេចក្តីជូនដំណើងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈលេខ ០៥១/០៨ កប/សជណ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៨ បានឱ្យដឹងថា និយោជិត កម្មករ កម្មការិនី ដែលបំរើការងារនៅតាមរោងចក្រ សហគ្រាស និងគ្រឹះស្ថានទាំងអស់ ត្រូវបានឈប់សម្រាកពីការងារចំនួនមួយថ្ងៃទៅបីថ្ងៃ ដើម្បីចូលរួមបោះឆ្នោតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ។

សេចក្តីជូនដំណឹងនោះមានខ្លឹមសារថា ម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងគ្រឹះស្ថានទាំងអស់ត្រូវបង្កលក្ខណៈ និងអនុញ្ញាតឱ្យនិយោជិត កម្មករ កម្មការិនី បានចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ឆ្នាំ២០០៨ ទៅតាមលក្ខណៈជាក់ស្តែង និងអាសយដ្ឋានពិតប្រាកដ ដែលពួកគេត្រូវទៅបោះឆ្នោត ÷

**ចំពោះរោងចក្រ សហគ្រាស និងគ្រឹះស្ថានដែលមានទីតាំងនៅរាជធានីភ្នំពេញ**

១- និយោជិត កម្មករ កម្មការិនី ដែលកំពុងបំរើការងារនៅភ្នំពេញ ហើយត្រូវទៅបោះឆ្នោតនៅរាជធានីភ្នំពេញ ត្រូវអនុញ្ញាតឱ្យឈប់សម្រាករយៈពេល១ថ្ងៃ គឺថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ។

២- និយោជិត កម្មករ កម្មការិនី ដែលកំពុងបំរើការងារនៅរាជធានីភ្នំពេញ ហើយត្រូវទៅបោះឆ្នោតនៅតាមបណ្តាខេត្ត ដូចជា កណ្តាល កំពង់ស្ពឺ និងកំពង់ឆ្នាំង ត្រូវអនុញ្ញាតឱ្យឈប់សម្រាករយៈពេល២ថ្ងៃ គឺនៅថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០០៨ ។

៣- និយោជិត កម្មករ កម្មការិនី ដែលកំពុងបំរើការងារនៅរាជធានីភ្នំពេញ ហើយត្រូវទៅបោះឆ្នោតនៅតាមបណ្តាខេត្ត ក្រុងដូចជា បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ធំ កំពត កោះកុង ក្រចេះ មណ្ឌលគីរី ព្រះវិហារ ព្រៃវែង ពោធិសាត់ រតនគីរី សៀមរាប ស្ទឹងត្រែង ស្វាយរៀង តាកែវ ប៉ៃលិន ឧត្តរមានជ័យ ក្រុងព្រះសីហនុ និងក្រុងកែប ត្រូវអនុញ្ញាតឱ្យឈប់សម្រាករយៈពេលបីថ្ងៃ គឺនៅថ្ងៃទី២៦-២៧-២៨ ខែកក្កដា ឆ្នាំ២០០៨ ។

**ដោយឡែកចំពោះរោងចក្រ សហគ្រាស គ្រឹះស្ថានដែលមានទីតាំងនៅខេត្ត-ក្រុងដទៃទៀតក្រៅពីរាជធានីភ្នំពេញ ត្រូវអនុញ្ញាតច្បាប់ជូនដល់ និយោជិត កម្មករ កម្មការិនី ទៅបោះឆ្នោតតាមការកំណត់ដូចក្នុងចំណុចទី១ និងចំណុចទី៣ ខាងលើ ដោយយកខេត្ត-ក្រុងនីមួយៗធ្វើជាទីតាំងដើម ដូចគ្នានឹងរាជធានីភ្នំពេញដែរ ។**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានបញ្ជាក់ផងដែរថា រាល់ការអនុញ្ញាតច្បាប់ជូននិយោជិត កម្មករ កម្មការិនី ក្នុងពេលទៅបោះឆ្នោត និយោជកត្រូវរក្សាទុកប្រាក់ឈ្នួល និងប្រាក់រង្វាន់ ដែលធ្វើការទៀងទាត់ជូន និយោជិត កម្មករ កម្មការិនី នៅដដែល និងពុំតម្រូវឱ្យបង្ហាញឯកសារផ្សេងៗ ដល់និយោជករបស់ខ្លួននៅពេល ដែលត្រឡប់មកវិញឡើយ ។ ចំពោះនិយោជិត កម្មករ កម្មការិនី ដែលអវត្តមានហួសច្បាប់អនុញ្ញាត ត្រូវទទួលខុសត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ សហគ្រាស និងគ្រឹះស្ថាន ។ ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ត្រូវខិតខំបើកប្រាក់ឈ្នួលឱ្យនិយោជិត កម្មករ កម្មការិនី ឱ្យបានមុនថ្ងៃទៅបោះឆ្នោត ។ បើពុំមានលទ្ធភាពបើកប្រាក់ឈ្នួលទេ សូមអនុញ្ញាតឱ្យនិយោជិត កម្មករ កម្មការិនី ខ្ចីប្រាក់ឈ្នួលមួយភាគ(បុរេប្រទាន)ជាមុនសិន។